**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៨ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង សរសេរជាអក្សរកាត់ថា **វ.ព.ក.ក.** និងមានទីតាំងស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ .-**

**វ.ព.ក.ក.** មានតួនាទីជាសេនាធិការឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំនិងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សាស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រីនិងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- ជ្រើសរើសសិក្ខាកាម សិស្ស និងនិស្សិតឱ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ពីលទ្ធផលការងាររបស់វិទ្យាស្ថានជូនរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

**វ.ព.ក.ក.** ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា លើកម្រិតជំនាញពាក់ព័ន្ធនឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ឬ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត សម្រាប់មួយកម្រិត
- កម្រិតសញ្ញាបត្រជាន់ខ្ពស់ ឬបរិញ្ញាបត្ររងបច្ចេកទេសឬឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យាឬឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៤ .-**

**ខ.ព.ក.ក.** ត្រូវដឹកនាំដោយនាយក/នាយិកា១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួន តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ខ.ព.ក.ក.** មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់និងការិយាល័យចំណុះ **ខ.ព.ក.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

**ខ.ព.ក.ក.** មានក្រុមប្រឹក្សាបច្ចេកទេសមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ **ខ.ព.ក.ក.** ។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

**ខ.ព.ក.ក.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួន សម្រាប់ជួយបំពេញការងារ។

**មាត្រា៧ .-**

**ខ.ព.ក.ក.** មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៨ .-**

សិក្ខាកាម សិស្ស និងនិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ **ខ.ព.ក.ក.** ដោយមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា៩ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **ខ.ព.ក.ក.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ខ.ព.ក.ក.** មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពនានាចំណុះ **ខ.ព.ក.ក.** ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយក/នាយិកា វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៥ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ✓
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកោះកុង
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ